**សម្តេចពិជ័យសេនា ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

## ផ្ញើជូន

**លោកជំទាវ VANN AMBER GERTRUDE**

*លោកជំទាវ ជាទីរាប់អាន,*

ភរិយាខ្ញុំ និងរូបខ្ញុំ បានទទួលដំណឹងដ៏ក្រៀមក្រំអំពីឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ដែលត្រូវជាស្វាមីលោកជំទាវ បានទទួលមរណភាពក្នុងជន្មាយុ ៩១ឆ្នាំ ដោយជរាពាធ ។

មរណភាពរបស់ឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** គឺជាការបាត់បង់បិតា ជីតា ប្រកបដោយព្រហ្មវិហារធម៌ និងក៏ជាការបាត់បង់នូវធនធានមនុស្សដ៏សំខាន់ម្នាក់ ដែលជាស្ថាបត្យករជើងចាស់ដ៏ល្បីល្បាញទាំងចំណេះដឹង និងទេពកោសល្យ បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវប្បធម៌របស់ជាតិ ។

ក្នុងឱកាស មានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមរំលែកទុក្ខនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងឲ្យដួងវិញ្ញាណក្ខន្ធឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិៗ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧

**ទៀ បាញ់**